សុន្ទរកថារបស់ **ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

**១៨ សីហា ២០១៧**

- សូមគោរព **លោកស្រី FUKUSHIMA Namiko** ប្រធានគម្រោងនៃអង្គការPHJប្រចាំកម្ពុជា
- សូមគោរព អស់លោក លោកស្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលបានប្រារព្ធពិធីចុះហត្ថលេខា សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន លើ"គម្រោងពង្រឹងប្រព័ន្ធថែទាំសុខភាពបឋមមាតា និងទារក នៅខេត្តកំពង់ចាម (ដំណាក់កាលទី3)" ដល់អង្គការPHJ។

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា US$120,000 ដល់អង្គការPHJ។ អង្គការPHJ នឹងពង្រឹងការគ្រប់គ្រងនៅតាមមណ្ឌលសុខភាព ផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តសុខភាព និងផ្តល់ការអប់រំដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ក្នុងស្រុកប្រតិបត្តិស្ទឹងត្រង់ ខេត្តកំពង់ចាម។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា តាមរយៈគម្រោងនេះ ប្រព័ន្ធសុខាភិបាលក្នុងតំបន់នេះ នឹងត្រូវបានពង្រឹង ហើយស្ថានភាពសុខភាព ក៏នឹងត្រូវបានកែលម្អកាន់តែល្អប្រសើរ។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុន សម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនដែលរស់នៅតាមកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថា គម្រោងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា៕

សូមអរគុណ!